ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 11 / 2016
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្ដីសម្រេចលើសំណើសុំ E434 និង E435 របស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើចំនួនពីរ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមេធាវីការពារក្ដី នួន ជា បានដាក់នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៦ ដែលសុំឱ្យទទួលយកឯកសារចំនួន ១៩ (ឯកសារ E434 សម្ងាត់) និង ឯកសារចំនួន ៩ (ឯកសារ E435) ធ្វើជាឯកសារភស្តុតាង (រួមគ្នាហៅថា "សំណើសុំ") ។ មេធាវីការពារក្ដីបានលើកឡើងថា ឯកសារទាំងនេះពាក់ព័ន្ធនឹងបញ្ហាមួយចំនួន រួមមានការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា តួនាទីរបស់ សោ ភឹម និង ការបះបោរផ្ទៃក្នុង។ សហព្រះរាជ-អាជ្ញាបានដាក់ចម្លើយតបរួម ជាឯកសារសម្ងាត់ទៅនឹងសំណើទាំងពីរនេះ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការទទួលយកឯកសារចំនួន ១១ ក្នុងចំណោមឯកសារដែលបានស្នើសុំ ដោយផ្អែកលើមូលដ្ឋាននៃភាពពាក់ព័ន្ធ និង/ឬ ភាពអាចជឿជាក់បាន តែមិនជំទាស់ទៅនឹងការទទួលឯកសារផ្សេងទៀតជាឯកសារភស្តុតាងទេ (ឯកសារ

E434/1)។

២. នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងតាមអ៊ីម៉ែលថា ឯកសារដែលបានស្នើសុំឱ្យទទួលយកជាឯកសារភស្តុតាងនៅក្នុងសំណើសុំទាំងពីរ ពាក់ព័ន្ធទៅនឹងសក្ខីកម្មនាពេលខាងមុខរបស់អ្នកជំនាញ Stephen Morris (2-TCE-98)។ មេធាវីការពារក្តី នួន ជា ក៏បានស្នើសុំការណែនាំពីអង្គជំនុំជម្រះអំពីស្ថានភាពនៃសំណើសុំនានា ដែលបានដាក់មុនថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ដែលជាថ្ងៃផុតកំណត់នៃការដាក់បង្ហាញបញ្ជីឯកសារទាក់ទិននឹងអ្នកជំនាញ Stephen Morris (2-TCE-98)។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយនៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ដែលសម្រេចទៅលើការទទួលយកឯកសារ ដែលបានស្នើសុំទាំងនោះធ្វើជាឯកសារភស្តុតាង។ ពាក់ព័ន្ធទៅនឹងសំណើ E434 អង្គជំនុំជម្រះបានទទួលយកឯកសារលេខរៀង ១, ១១ និង ១២ និង បានបដិសេធពុំទទួលយកឯកសារផ្សេងទៀតនោះឡើយ។ អង្គជំនុំជម្រះក៏បានបដិសេធលើសំណើរបស់សហព្រះរាជ-អាជ្ញានៅក្នុងឯកសារ E434/1 ដែលបានសុំកំណត់អត្តសញ្ញាណ និង កោះហៅសាក្សីបន្ថែមមួយរូប។ ពាក់ព័ន្ធនឹងសំណើ E435 អង្គជំនុំជម្រះបានទទួលយកឯកសារចំនួន ៨ ធ្វើជា ឯកសារភស្តុតាង និង បានបដិសេធមិនទទួលយកឯកសារផ្សេងទៀតឡើយ (ប្រតិចារឹក សវនាការថ្ងៃទី ១១ ខែ តុលា ទំព័រ ៨៣ សេចក្តីព្រាង)។ តទៅនេះ អង្គជំនុំជម្រះផ្តល់សម្អាង ហេតុដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន។

៣. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំ-ជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុន

ពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំនេះ គឺជាភស្តុតាងដោះបន្ទុកដែលតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (*សូមមើល* ឯកសារ E319/36/2)។

៤. ជាដំបូង អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ឯកសារចំនួន ២៧ ក្នុងចំណោមឯកសារ ២៨ ដែលបានស្នើសុំ អាចរកបានជាសាធារណៈ មុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះ ចំណែកឯកសារផ្សេងទៀតអាចរកបានចាប់ពីខែ មិថុនា ឆ្នាំ ២០១៤ (ឯកសារ E434 ឯកសារ ១៦)។ អង្គជំនុំជម្រះយល់ឃើញថា ក្នុងកាលៈទេសៈទាំងនេះ សំណើទាំងនេះគួរតែត្រូវបានដាក់ស្នើឆាប់ជាងនេះ។ ដើម្បីគាំទ្រដល់ភាពយឺតយ៉ាវក្នុងការដាក់សំណើរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានលើកឡើងថាពួកគេមានធនធានតិចតួច ហើយលទ្ធភាពស៊ើបអង្កេតដោយឯករាជ្យនោះក៏មានកម្រិតដែរ ការលើកឡើងនេះមិនសមហេតុផលឡើយ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំទាំងនេះមិនបានដាក់ទាន់ពេលវេលា ហើយនៅពេលនេះ អង្គជំនុំជម្រះពិចារណាលើថាតើការទទួលយកឯកសារទាំងនេះធ្វើជាឯកសារភស្តុតាង ផ្តល់ជាប្រយោជន៍យុត្តិធម៌ដែរ ឬ យ៉ាងណា។

៥. អង្គជំនុំជម្រះជាដំបូងកត់សម្គាល់ថា ឯកសារចំនួនបីដែលមេធាវីការពារក្តី នួន ជា ស្នើសុំឱ្យទទួលយកជាឯកសារភស្តុតាងអាចរកបានជាភាសាចិនតែប៉ុណ្ណោះ (ឯកសារលេខរៀង ១៤ និង ១៥ នៅក្នុងសំណើ E434 និង ឯកសារលេខរៀង ១ នៅក្នុងសំណើ E435)។ ជាងនេះទៀត ឯកសារមួយទៀតអាចរកបានតែជាភាសាហូឡង់ប៉ុណ្ណោះ (ឯកសារ ១៧ នៅក្នុងសំណើ E434)។ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា វាជាកាតព្វកិច្ចរបស់ក្រុមមេធាវីការពារក្តីក្នុងការបកប្រែឯកសារចាំបាច់ដើម្បីដាក់ឯកសារទាំងនោះជាភាសាផ្លូវការរបស់តុលាការ។ ទោះបីជាអង្គជំនុំជម្រះធ្លាប់បានរង់ចាំការបកប្រែឯកសារនានា និង បានសម្រេចលើការទទួល

យកធ្វើជាឯកសារភស្តុតាងនៅជិតដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី នាពេលនេះ អង្គជំនុំជម្រះពឹងផ្អែកទៅលើសេចក្តីពិពណ៌នានៃឯកសារទាំងនេះរបស់មេធាវីការពារក្តី នួន ជា។

៦. ជាដំបូង អង្គជំនុំជម្រះពិភាក្សាលើឯកសារដែលបានស្នើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាងនៅក្នុងសំណើ E434។ អង្គជំនុំជម្រះទទួលយកឯកសារលេខរៀង ១, ១១ និង ១២ និង បដិសេធមិនទទួលយកឯកសារផ្សេងទៀត ផ្អែកលើសម្អាងហេតុនានាដូចខាងក្រោម។

៧. ឯកសារលេខរៀង ១ គឺជាបញ្ជីឯកសារយោងនៅក្នុងសៀវភៅមួយដែលនិពន្ធដោយ William DUICKER ដែលមួយផ្នែកនៃបញ្ជីនោះ ត្រូវបានទទួលយកជាឯកសារភស្តុតាង និង លើកយកមកពិភាក្សានៅក្នុងសវនាការរួចមកហើយ។ នៅត្រង់ចំណុចនេះ អង្គជំនុំជម្រះបានលើកសំណួរនានាទាក់ទិននឹងប្រភពដែលលោក DUICKER យកមកសម្អាងក្នុងការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងសៀវភៅរបស់លោក (*សូមមើល* ឯកសារ E3/7340; ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ ៦៨-៧១ សេចក្តីព្រាង)។ បញ្ជីឯកសារយោងមានបញ្ជីសៀវភៅ និង អត្ថបទនានាដែលលោក DUICKER យកមកសម្អាង ហើយអង្គជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍យុត្តិធម៌ក្នុងការវាយតម្លៃលើប្រភពទាំងពីររួមគ្នា ហេតុនេះអង្គជំនុំជម្រះទទួលឯកសារលេខរៀង ១ ធ្វើជាឯកសារភស្តុតាង។

៨. ឯកសារលេខរៀង ២ ដល់ ៥ ជាអត្ថបទនិពន្ធដោយ 2-TCE-83 ដែលពិពណ៌នាអំពីតួនាទីរបស់ សោ ភឹម ព្រមទាំងការចូលរួមរបស់វៀតណាមក្នុងការឈ្លានពានកម្ពុជា និង គាំទ្រដល់ការបះបោរ។ ភាគីបានទទួលការជូនដំណឹងតាមអ៊ីម៉ែលនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ថា អ្នកជំនាញ 2-TCE-83 មិនមានលទ្ធភាពក្នុងការមកផ្តល់សក្ខីកម្មក្នុងសំណុំរឿងនេះទេ។ ដោយសារពុំមានសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-83 ពាក់ព័ន្ធទៅនឹងប្រភព និង មូលដ្ឋាននានានៃសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញរូបនេះនោះ អង្គជំនុំជម្រះយល់ឃើញថា វាពុំមែនជាប្រយោជន៍នៃយុត្តិធម៌ក្នុងការទទួលយកអត្ថបទនេះជាឯកសារភស្តុតាង នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនោះឡើយ។

៩. ឯកសារលេខរៀង ៦ និង ៧ គឺជាអត្ថបទដែលនិពន្ធដោយអ្នកកាសែតម្នាក់ឈ្មោះ Anthony

PAUL ដែលមានព័ត៌មានទាក់ទិននឹងការបែកបាក់ផ្ទៃក្នុង និង លទ្ធភាពនៃការបះបោរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារពុំមានសក្ខីកម្មរបស់ Anthony PAUL ពាក់ព័ន្ធទៅនឹងប្រភព និង មូលដ្ឋាននានានៃសេចក្តីសន្និដ្ឋានរបស់គាត់ អង្គជំនុំជម្រះយល់ឃើញថា វាពុំមែនជាប្រយោជន៍យុត្តិធម៌ក្នុងការទទួលយកអត្ថបទនេះជាឯកសារភ័ស្តុតាង នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនោះឡើយ។

១០. ឯកសារលេខរៀង ៨ ដល់លេខ ១០ ទាក់ទិននឹងកិច្ចប្រជុំជាន់ខ្ពស់រវាងសហរដ្ឋអាមេរិក និង ឥណ្ឌូនេស៊ី ដែលបានពិភាក្សាអំពីមហិច្ឆតារបស់វៀតណាមក្នុងការពង្រីកទឹកដីទៅក្នុងកម្ពុជា និងក្នុងតំបន់។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារនានាដែលជាព័ត៌មានបន្ត មិនពាក់ព័ន្ធ ឬ សមស្របក្នុងការយកមកសំអាងបង្ហាញពីអង្គហេតុ ដែលកំពុងពិនិត្យក្នុងសំណុំរឿងនេះឡើយ ដោយសារឯកសារទាំងនេះទាក់ទងនឹងកិច្ចប្រជុំនានា ដែលមន្ត្រីជាន់ខ្ពស់ទាំងនោះ ប៉ាន់ស្មានអំពីមហិច្ឆតារបស់វៀតណាមក្នុងការពង្រីកទឹកដី និង ឥទ្ធិពលផ្នែកនយោបាយរបស់វៀតណាមនៅក្នុងតំបន់។

១១. ឯកសារលេខ ១១ និង ១២ លើកឡើងពីព័ត៌មានផ្ទៃក្នុង អំពីមហិច្ឆតា និង គោលនយោបាយរបស់វៀតណាមពាក់ព័ន្ធនឹងកម្ពុជា និង នៅក្នុងតំបន់ ដែលបានមកពីមន្ត្រីថ្នាក់កំពូលដែលផ្តាច់ខ្លួនចេញពីបក្សកុម្មុយនីស្តវៀតណាម។ ទោះបីជាពុំមានសក្ខីកម្មពីបុគ្គលទាំងនេះដែលប៉ះពាល់ដល់ទម្ងន់នៃភ័ស្តុតាងនេះយ៉ាងណាក៏ដោយ មន្ត្រីថ្នាក់ខ្ពស់ទាំងនោះស្ថិតក្នុងតួនាទីដែលមានលទ្ធភាពក្នុងការយល់ដឹងផ្ទាល់ពីបញ្ហាទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះគួរត្រូវទទួលយកធ្វើជាឯកសារភ័ស្តុតាង ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និង ត្រូវយកមកវាយតម្លៃរួមគ្នាជាមួយនឹងភ័ស្តុតាងផ្សេងទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។

១២. ឯកសារលេខរៀង ១៣ មានពីរជំពូក និង លេខចុងទំព័រ យកចេញពីសៀវភៅមួយនិពន្ធដោយប្រវត្តិវិទូឈ្មោះ Margaret SLOCOMB ដែលពិពណ៌នាពីមហិច្ឆតារបស់វៀតណាមចំពោះកម្ពុជា និង ការបះបោរផ្ទៃក្នុងនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ ដោយសារពុំមានសក្ខីកម្មរបស់ Margaret SLOCOMB ពាក់ព័ន្ធទៅនឹងប្រភព និង មូលដ្ឋាននានានៃសេចក្តីសន្និដ្ឋានរបស់គាត់ អង្គជំនុំជម្រះយល់ឃើញថា វាពុំមែនជាប្រយោជន៍យុត្តិធម៌ក្នុងការទទួលយកជំពូកទាំងពីរដែលគាត់បាននិពន្ធធ្វើជាឯកសារភ័ស្តុតាងនៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរ

ការនីតិវិធីជំនុំជម្រះនោះឡើយ។

១៣. តាមការពិពណ៌នាអំពីឯកសារដែលលើកឡើងដោយមេធាវីការពារក្តី នួន ជា ឯកសារលេខរៀង១៤ និង ១៥ ជាអត្ថបទជាភាសាចិន រៀបរាប់អំពីអំឡុងពេលបន្ទាប់ពីការឈ្លានពានរបស់វៀតណាមមកលើកម្ពុជានៅក្នុងឆ្នាំ ១៩៧៩ និង អំពើឃោរឃៅរបស់កងកម្លាំងវៀតណាមមកលើប្រជាជនកម្ពុជា។ អង្គជំនុំជម្រះសន្និដ្ឋានថា របាយការណ៍ដែលមានព័ត៌មានបន្តទាំងនេះ មិនពាក់ព័ន្ធ ឬ មិនសមស្របក្នុងការយកមកសម្អាងដើម្បីបង្ហាញពីអង្គហេតុដែលកំពុងពិនិត្យក្នុងរឿងក្តីនេះឡើយ ដោយសារតែរបាយការណ៍ទាំងនេះពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានាដែលមិនស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយវាមានបញ្ហាទាក់ទិននឹងភាពជឿជាក់បាន ដោយសារភាពមិនច្បាស់លាស់ជុំវិញអត្តសញ្ញាណរបស់អ្នកនិពន្ធ និង ប្រភពបន្ថែមទៅលើមតិយោបល់ផ្នែកនយោបាយដែលបានលើកឡើងនៅក្នុងអត្ថបទទាំងនេះ។

១៤. ក្នុងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ឯកសារលេខរៀង ១៦ និង ១៧ ជាឯកសារដែលបង្ហាញថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺជារដ្ឋាភិបាលស្របច្បាប់ ហើយមានទំនាក់ទំនងអន្តរជាតិជាជាងនៅឯកោដាច់តែឯង។ ឯកសារលេខ ១៦ គឺជាការវិភាគរបស់បណ្ណសារដ្ឋានអាល្លឺម៉ង់ខាងកើតអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារលេខរៀង ១៧ គឺជាការឆ្លើយតបមួយរបស់រដ្ឋាភិបាលហូឡង់ទៅនឹងសំណួរទាក់ទិននឹងទំនាក់ទំនងជាមួយកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារលេខរៀង ១៧ ពុំទាន់បានបកប្រែពីភាសាហូឡង់នៅឡើយ។ តាមរយៈការពិនិត្យលើខ្លឹមសារនៃឯកសារទី ១ និង សេចក្តីសង្ខេបនៃឯកសារទី ២ អង្គជំនុំជម្រះសន្និដ្ឋានថា ឯកសារទាំងនេះពុំពាក់ព័ន្ធទៅនឹងការចោទប្រកាន់នានានៅក្នុងរឿងក្តីនេះទេ ហេតុនេះ អង្គជំនុំជម្រះបដិសេធមិនទទួលយកឯកសារទាំងនេះធ្វើជាឯកសារភ័ស្តុតាង។

១៥. ឯកសារលេខរៀង ១៨ ជាប្រតិចារិកនៃកិច្ចសម្ភាសន៍មួយរបស់បុគ្គលមួយរូប ដែលគេមិនស្គាល់ឈ្មោះ ដែលបានធ្វើឡើងដោយអ្នកកាសែតម្នាក់ឈ្មោះ Sara COLM។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះធ្លាប់បានបដិសេធមិនទទួលយកឯកសារនេះធ្វើជាឯកសារភ័ស្តុ-តាង ដោយសារវាជាចម្លើយពាក់ព័ន្ធតែនឹងអំពើ និង ការប្រព្រឹត្តិរបស់ជនជាប់ចោទ និងដោយសារភាគីមានឱកាសក្នុងការសួរដេញដោលអ្នករៀបចំកិច្ចសម្ភាសន៍នៅក្នុងសវនាការ (*សូម*

*មើល* ឯកសារ E299 កថាខណ្ឌ ១៧, ២៥; ឯកសារ E299.2, ERN ជាភាសាអង់គ្លេស 00945085 យោងទៅឯកសារ IS19.160)។ ស្រដៀងគ្នាដែរ នៅក្នុងសំណុំរឿងនេះ និងដោយផ្អែកលើសម្អាងហេតុដូចគ្នា អង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះមិនគួរត្រូវបានពិចារណាទទួលយកធ្វើជាឯកសារភស្តុតាងឡើយ។ ជាងនេះទៀត ឯកសារនេះគឺជាកិច្ចសម្ភាសន៍ពីប្រភពដែលមិនស្គាល់ ហេតុនេះវាមានទាក់ទិននឹងបញ្ហាភាពជឿជាក់បាន ហើយវាមានតម្លៃជាភស្តុតាងតិចតួច។ ក្រៅពីនេះ ឯកសារនេះហាក់ស្តែងឲ្យឃើញពីចំណេះដឹងរបស់អ្នកផ្តល់កិច្ចសម្ភាសន៍លើបញ្ហាជាក់ស្តែងមួយចំនួន ដែលបានមកពីចម្លើយសារភាពនានាដែលបង្ហាញហានិភ័យជាក់ស្តែងតាមរយៈការធ្វើទារុណកម្ម ហេតុនេះវាពុំអាចទទួលយកធ្វើជាឯកសារភស្តុតាងបាននោះឡើយ។ ហេតុដូចនេះ អង្គជំនុំជម្រះបដិសេធមិនទទួលយកឯកសារលេខរៀង ១៨ ធ្វើជាឯកសារភស្តុតាង។

១៦. ទាក់ទិននឹងចំណុចនេះ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបដោយស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ កំណត់អត្តសញ្ញាណ និង កោះហៅបុគ្គលដែលបានផ្តល់កិច្ចសម្ភាសន៍នៅក្នុងឯកសារលេខរៀង១៨មកផ្តល់សក្ខីកម្ម។ សហ-ព្រះរាជអាជ្ញាលើកឡើងថា ភស្តុតាងរបស់បុគ្គលរូបនេះមានភាពពាក់ព័ន្ធខ្លាំង ដោយសារវាមានការអះអាងថា បញ្ជាមួយចំនួនរបស់ ប៉ុល ពត ត្រូវបានផ្លាស់ប្តូរ ហើយក៏បានលើកឡើងថា ខៀវ សំផន បានអានចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ឲ្យកម្មាភិបាលស្តាប់។ សហព្រះរាជអាជ្ញាបានលើកឡើងថា ប្រសិនបើបុគ្គលរូបនេះ មិនមានលទ្ធភាពមកធ្វើសក្ខីកម្ម ឯកសារនេះគួរតែអាចទទួលយកធ្វើជាឯកសារភស្តុតាងដដែល ហើយការដែលមិនអាចមកធ្វើសក្ខីកម្មរបស់សាក្សីរូបនេះ នឹងត្រូវយកមកពិចារណានៅពេលវាយតម្លៃលើទម្ងន់នៃភស្តុតាងនោះ (ឯកសារ E434/1 កថាខណ្ឌ ២៦, ៤១)។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងសំណើសុំនេះ ដោយផ្អែកលើមូលដ្ឋានថា វាប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើដំណើរការឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និង សិទ្ធិរបស់មេធាវីការពារក្តី ហើយថា អង្គជំនុំជម្រះមិនគួរជួយបំពេញនូវភាពខ្វះខាតរបស់សហព្រះរាជអាជ្ញានោះឡើយ (ឯកសារ E434/1/1)។ អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលសុំកំណត់អត្តសញ្ញាណ និង កោះហៅសាក្សីបន្ថែម ដោយសារសំណើសុំនេះបានដាក់យឺតពេល និងបណ្តាលឲ្យមានការពន្យារពេលដល់កិច្ចដំណើរការនៃនីតិវិធីសវនាការដោយមិនសមស្រប ។ សហព្រះរាជអាជ្ញាមានឱ

កាសគ្រប់គ្រាន់ក្នុងការដាក់សំណើសុំនេះមុនកាលបរិច្ឆេទនៃការដាក់សំណើរខាងលើ តែសហព្រះរាជអាជ្ញាមិនបានដាក់សំណើសុំទាន់ពេលវេលានោះទេ។

១៧. ឯកសារលេខរៀង ១៩ ជាអត្ថបទសិក្សានិពន្ធដោយ Stephen HEDER (2-TCE-87) ដែលត្រូវបានលោកយកទៅពិភាក្សានៅសាកលវិទ្យាល័យជាតិអូស្ត្រាលី។ ក្នុងអត្ថបទនេះ Stephen HEDER (2-TCE-87) បានពិភាក្សាលើការវិភាគ និង ទស្សនៈរបស់គាត់ ទាក់ទិននឹងការពិតនៃឯកសារនានាដែលបានទុកចោលនៅមន្ទីរសន្តិសុខ ស-២១ រួមមានកំណត់ហេតុលម្អិតស្តីពីការធ្វើទារុណកម្ម។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទស្សនៈរបស់ Stephen HEDER (2-TCE-87) ពាក់ព័ន្ធនឹងការពិតនៃចម្លើយសារភាពទាំងនេះមិនអាចទទួលយកបានទេ។ អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃដោយខ្លួនឯងអំពីការប្រើប្រាស់ភស្តុតាងនេះ អនុលោមទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម (ឯកសារ E350/8)។

១៨. នាពេលនេះ អង្គជំនុំជម្រះពិចារណាលើឯកសារនានាដែលបានស្នើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាងនៅក្នុងសំណើ E435។ អង្គជំនុំជម្រះសាលាដំបូង ទទួលយកឯកសារលេខរៀង ១៨ និង បដិសេធមិនទទួលយកឯកសារផ្សេងទៀតធ្វើជាឯកសារភស្តុតាង ដោយផ្អែកលើសម្អាងហេតុនានាដូចខាងក្រោម។

១៩. តាមការពិពណ៌នាអំពីឯកសារដែលលើកឡើងដោយមេធាវីការពារក្តី នួន ជា ឯកសារលេខរៀងទី ១ គឺជាអត្ថបទមួយដែលបានចុះផ្សាយនៅក្នុងកាសែត People's Daily ជាភាសាចិននៅខែ កុម្ភៈ ឆ្នាំ ១៩៧៩ អាចរកបានជាភាសាចិនតែមួយភាសា ដែលពិភាក្សាអំពីប្រវត្តិមហិច្ឆតាវាតទីរបស់វៀតណាមនៅក្នុងតំបន់ និង ការឈ្លានពានរបស់វៀតណាមលើកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញថា ការចុះផ្សាយពីកាសែតជាផ្លូវការរបស់បក្សកុម្មុយនីស្តចិនដែលមិនស្គាល់ប្រភព មិនពាក់ព័ន្ធ ឬ មិនសមស្របក្នុងការយកមកធ្វើជាសម្អាងបង្ហាញពីអង្គហេតុដែលកំពុងពិនិត្យក្នុងសំណុំរឿងនេះឡើយ។

២០. ឯកសារលេខរៀង ២ ដល់លេខ៧ រួមមានអត្ថបទកាសែតជាភាសាចិន វិចារណកថាជាភាសាចិន សេចក្តីដកស្រង់មួយចេញពីរបាយការណ៍ផ្ទៃក្នុងផ្ញើជូនបក្សកុម្មុយនីស្តចិននៅខែ មីនា ឆ្នាំ

១៩៧៣ និង សេចក្ដីដកស្រង់មួយចេញពីសុន្ទរកថានានាដែលរដ្ឋមន្ត្រីការបរទេសចិនធ្វើនៅខែកក្កដា ឆ្នាំ ១៩៧៧។ ឯកសារទាំងនេះរួមមានទស្សនៈ ការវាយតម្លៃ និង ការវិភាគទៅលើមហិច្ឆតារបស់វៀតណាមនៅអាស៊ីអាគ្នេយ៍ និង ជម្លោះរវាងវៀតណាម និង កម្ពុជា និង ការធ្វើអន្តរាគមន៍របស់វៀតណាមនៅកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញថា សម្ភារៈទាំងនេះមិនពាក់ព័ន្ធ ឬ មិនសមស្របក្នុងការយកមកសម្អាង ដើម្បីបង្ហាញពីអង្គហេតុដែលកំពុងពិនិត្យក្នុងសំណុំរឿងនេះឡើយដោយសារឯកសារទាំងនេះមានរបាយការណ៍ដែលមានព័ត៌មានបន្ត និង ការប៉ាន់ស្មានអំពីតួនាទីរបស់វៀតណាមនៅក្នុងតំបន់។ អង្គជំនុំជម្រះយល់ឃើញផងដែរថា ឯកសារទាំងនេះមានបញ្ហាលើភាពជឿជាក់បាន ជាពិសេសត្រង់ទស្សនៈមួយចំនួនដែលត្រឹមតែឆ្លុះបញ្ចាំងនូវការវិភាគផ្នែកនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តចិន ទាក់ទិននឹងប្រទេសមួយដែលចិនមានជម្លោះជាមួយ។

២១. ឯកសារលេខរៀង ៨ រៀបរាប់អំពីសន្និសីទកាសែតមួយ ដែលបានធ្វើឡើងដោយព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ នៅទីក្រុងប៉េកាំង នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៧៩។ អត្ថបទនេះដកស្រង់ការឆ្លើយតបរបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទៅនឹងសំណួរនានា ដែលព្រះអង្គបានថ្កោលទោសការឈ្លានពានរបស់វៀតណាមមកលើប្រទេសកម្ពុជា និង ផ្ដល់ការសង្កេតរបស់ព្រះអង្គលើស្ថានភាពដែលព្រះអង្គបានអង្កេតឃើញនៅពេលទស្សនកិច្ចតាមតំបន់ជនបទនៅក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះបានទទួលយកព្រះរាជសុន្ទរកថារបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដែលព្រះអង្គបានថ្លែងនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៩ នៅចំពោះមុខក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លើបញ្ហាស្រដៀងគ្នា ដែលបានយកធ្វើជាឯកសារភ័ស្តុតាងរួចមកហើយ (ឯកសារ E3/7335)។ ជាងនេះទៀត អង្គជំនុំជម្រះក៏បានទទួលយកសៀវភៅមានចំណងជើង “Prisonnier des Khmers Rouges” (“អ្នកទោសខ្មែរក្រហម”) ដែលជាព្រះរាជនិពន្ធរបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ (ឯកសារ E3/2813) ដែលព្រះអង្គបានពិពណ៌នាអំពីកាលៈទេសៈនានាជុំវិញសន្និសីទកាសែតនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៧៩។ ហេតុនេះ អង្គជំនុំជម្រះជឿជាក់ថាភ័ស្តុតាងនេះ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ ហើយវាជាប្រយោជន៍ដល់យុត្តិធម៌ក្នុងការវាយតម្លៃរួមលើប្រភពនៃឯកសារ និង សម្ភារៈទាំងនេះ។ ហេតុនេះ អង្គជំនុំជម្រះទទួលយកឯកសារលេខរៀង ៨ នេះធ្វើជាឯកសារភ័ស្តុតាង។

២២. ឯកសារលេខរៀង ៩ ជាសៀវភៅដែលចងក្រងមតិយោបល់របស់មន្ត្រីការបរទេស និង បញ្ញវ័ន្តថៃ ស្ដីពីការឈ្លានពានរបស់វៀតណាមនៅកម្ពុជា និង មហិច្ឆតារបស់វៀតណាមក្នុងការពង្រីកទឹកដី។ អង្គជំនុំជម្រះយល់ឃើញថា សម្ភារៈទាំងនេះមិនពាក់ព័ន្ធ ឬ មិនសមស្របក្នុងការយកមកសម្អាងដើម្បីបង្ហាញពីអង្គហេតុដែលកំពុងពិនិត្យក្នុងសំណុំរឿងនេះឡើយ។ អង្គជំនុំជម្រះ យល់ឃើញផងដែរថាឯកសារនេះមានបញ្ហាលើភាពជឿជាក់បាន ជាពិសេសត្រង់ទស្សនៈមួយចំនួនដែលផ្ទុះបញ្ចាំងនូវការវិភាគផ្នែកនយោបាយផ្លូវការពីទស្សនៈរបស់ថៃចំពោះប្រទេសជិតខាងដែលបានចូលពាក់ព័ន្ធក្នុងជម្លោះមួយដែលថៃមានផលប្រយោជន៍ក្នុងនោះ។

២៣. ផ្អែកតាមសម្អាងហេតុដែលបានរៀបរាប់ខាងលើ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារលេខ ១, ១១ និង ១២ ដែលយោងនៅក្នុងសំណើ E434 និង ដាក់លេខយោងទៅតាមលំដាប់លំដោយជាឯកសារ E3/10706, E3/10707 និង E3/10708។ អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយកឯកសារផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងក៏បដិសេធមិនទទួលយកសំណើរបស់សហព្រះរាជអាជ្ញាផងដែរ ដែលបានសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ធ្វើការកំណត់អត្តសញ្ញាណបុគ្គលដែលបានផ្ដល់កិច្ចសម្ភាសន៍នៅឯកសារលេខរៀង ១៨ និង កោះហៅបុគ្គលនោះមកផ្ដល់សក្ខីកម្ម។ ទាក់ទិននឹងសំណើ E435 អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារលេខរៀង ៨ ធ្វើជាឯកសារភ័ស្តុតាង និង ដាក់លេខយោងជាឯកសារ E3/10709។ អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយកឯកសារផ្សេងទៀត។

២៤. អនុស្សរណៈនេះ ជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ E434 និង E435។